YUNNAN DAILY PRESS GROUP
No.193

ប្រទេសចិន-ខេត្តយូនណាន

ខ្មែរភ្នំពេញប្រចាំថ្ងៃ

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8007 ថ្ងៃសុក្រ ទី16 ខែសីហា ឆ្នាំ2019

ការអភិវឌ្ឍន៍ដោយបៃតងក្លាយជាគំនិតឯកភាពគ្នាក្នុងសង្គមចិន

រដ្ឋបាលស្រុកឈើវ ប៉ែនៃខេត្តយូនណានផ្តោតសំខាន់ទៅលើការគ្រប់គ្រងបរិស្ថានក្នុងរមណីយដ្ឋានថ្នាក់ជាតិ ភូដីហ៊ី ធ្វើឱ្យអេកូ-បរិស្ថាន ត្រូវបានកែលម្អជាបន្តបន្ទាប់

កាលពីថ្ងៃទី ២៧ ដល់ទី ២៨ ខែកក្កដា ឆ្នាំ២០១៩ វេទិការាលខ្សាច់អន្តរជាតិ ឃ្យូពូឈី លើកទី៧ បានប្រារព្ធនៅតំបន់ស្វយ័តម៉ុងហ្គោលីក្នុង ។ ក្រោមកិច្ចខិតខំប្រឹងប្រែងរយៈពេលពា០ឆ្នាំ វាលខ្សាច់ឃ្យូពូឈីក្នុងតំបន់ម៉ុងហ្គោលីក្នុងមានទំហំមួយភាគបីបានក្លាយទៅជាទឹកដីបៃតង ហើយក្លាយទៅជាវាលខ្សាច់តែមួយគត់ដែលត្រូវបានគ្រប់គ្រង និងដោះស្រាយជាទូទៅលើពិភពលោក។ បច្ចុប្បន្នទស្សនៈអភិវឌ្ឍន៍ដោយបៃតងបានជ្រៀតចូលក្នុងក្រអៅបេះដូងរបស់ប្រជាជនចិនចំណែកគុណភាពបរិស្ថានចិនក៏បានត្រូវកែលម្អជាបន្តបន្ទាប់ដែរ ។

-មេឃកាន់តែមានពណ៌ខៀវ

លោក កៅ ស្បៀង រស់នៅក្នុងក្រុងប៉េកាំងយូរឆ្នាំហើយ ។ លោកបានប្រាប់អ្នកកាសែតថា "កាលមុនពេលធ្លាក់ភ្លៀងយើងត្រូវរកកន្លែងភៀសខ្លួនបើពុំនោះទេ មុខជានឹងប្រឡាក់ភក់លើខ្លួន។ តែសព្វថ្ងៃទឹកភ្លៀងស្អាតជាងមុន ។ ក្នុងអំឡុងពេលពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៨ សាលារដ្ឋបាលក្រុងប៉េកាំងបានចាត់វិធានការមួយចំនួនធំដើម្បីជំរុញការប្រើប្រាស់ថាមពលស្អាត ដូចជាយកឧស្ម័ន និងអគ្គិសនីជំនួសធ្យូងថ្មជាដើម ។ ដង់ស៊ីតេPM ២,៥ ប្រចាំឆ្នាំជាមធ្យមបានធ្លាក់ចុះ៤៣,៣ភាគរយ ចំណែកចំនួនថ្ងៃដែលមានគុណភាពខ្យល់អាកាសស្របនឹងស្តង់ដារក្នុងមួយឆ្នាំបានកើនឡើងពី១៧៥ ថ្ងៃ ដល់ ២៧ ថ្ងៃ ។

ក្រោយពីប្រទេសចិនអនុវត្តន៍ "ផែនការសកម្មភាពស្តីពីការគ្រប់គ្រងការបំពុលបរិស្ថានខ្យល់អាកាស" នៅឆ្នាំ ២០១៣រៀងមក ប្រទេសចិនបានទទួលលទ្ធផលជាក់ស្តែងក្នុងការគ្រប់គ្រងបរិស្ថានខ្យល់អាកាស ។ នៅឆ្នាំ ២០១៨ អត្រានៃចំនួនថ្ងៃដែលមានអាកាសធាតុល្អក្នុងប្រទេសចិនគឺ៧៩,៣ភាគរយ ។ គុណភាពខ្យល់អាកាសក្នុងប្រទេសចិនត្រូវបានកែលម្អជាបន្តបន្ទាប់ ។

-ទឹកកាន់តែមានភាពស្អាត

បច្ចុប្បន្នបឹងអឺហៃដែលជាបឹងទឹកសាបលើខ្ពង់រាបធំទី២ នៅខេត្តយូនណានកំពុងប្រឈមនឹងបញ្ហាបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីការរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងតំបន់ ។ ដូច្នេះរដ្ឋបាលខេត្តយូនណានបានចាត់វិធានការតឹងរ៉ឹង ដើម្បីគ្រប់គ្រងការបំពុលបរិស្ថាន ។ រដ្ឋបាលខេត្តយូនណានបានវាយចោលសំណង់ខុសច្បាប់ និងបំបិទទ្វារ នៃសណ្ឋាគារចំនួនជាងមួយពាន់នៅមាត់បឹងអឺហៃ ហើយសំណូមពរឱ្យសណ្ឋាគារទាំងនោះដំឡើងប្រព័ន្ធសម្អាតទឹកកខ្វក់ស្របតាមស្តង់ដារទើបអាចបើកទ្វារបាន ។

បើប្រៀបធៀបនឹងឆ្នាំ ២០១២ អត្រាទឹកលើផ្ទៃដីដែលមានគុណភាពល្អក្នុងប្រទេសចិននៅឆ្នាំ ២០១៧ មានកម្រិតកាន់តែខ្ពស់ ។ តំបន់ដីសើមនៃប្រទេសចិនមានទំហំ៥៣,៦លានហិកតា ជាប់លំដាប់លេខ ១ ក្នុងទ្វីបអាស៊ី និងលំដាប់លេខ ៤ លើពិភពលោក ។

-ភ្នំកាន់តែមានពណ៌បៃតង

កាលមុនការអភិវឌ្ឍឧស្សាហកម្មនៅស្រុកហ្គាតីងក្រុងលីជាំងខេត្តយូនណានគឺអាស្រ័យទៅលើអាជីវកម្ម រ៉ែធ្យូងថ្ម ដែលបានប៉ះពាល់ដល់អេកូ-បរិស្ថានក្នុងតំបន់។ ប៉ុន្មានឆ្នាំនេះរដ្ឋបាលស្រុកហ្គាតីងបានបំបិទអណ្តូង រ៉ែធ្យូងថ្មហើយកែលម្អរចនាសម្ព័ន្ធ ឧស្សាហកម្មបង្កើត ចម្ការស្វាយលើភ្នំរ៉ែដែលបានធ្វើឱ្យភ្នំគ្របដណ្តប់ដោយពណ៌បៃតងជាថ្មីម្តងទៀត។

ក្រោយពីឆ្នាំ ២០១២ រៀងមក ប្រទេសចិនបានដាំព្រៃឈើ ៣៣,៩ លានហិកតា ដែលបានធ្វើឱ្យព្រៃឈើចិនមានទំហំ២០៨លានហិកតា ។ អត្រាគ្រប់ដណ្តប់ដោយព្រៃឈើគឺ ២១,៦៦ ភាគរយ បរិមាណឈើកើនឡើងដល់ ១៥.១៣៧លានម៉ែត្រគុប។ ប្រទេសចិនបានក្លាយទៅជាប្រទេសដែលមានធនធានព្រៃឈើកើនឡើងលឿនជាងគេលើពិភពលោក ។

●ឯកឧត្តម ស៊ុ ជីនភីង បកស្រាយពីការការពារអេកូ-បរិស្ថាន

នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៨ ឯកឧត្តម ស៊ុ ជីនភីង បានថ្លែង សុន្ទរកថាក្នុងកិច្ចប្រជុំស្តីពីការការពារអេកូបរិស្ថានទូទាំងប្រទេសចិនថា ទឹកបៃតង និងភ្នំ-បៃតងគឺជាភ្នំមាស និង ភ្នំប្រាក់ ។ យើងត្រូវអនុវត្តន៍តាមទស្សនៈអភិវឌ្ឍ ដែលមានលក្ខណៈថ្មៃប្រឌិតថ្មី សម្របសម្រួល មានពណ៌បៃតង បើកទូលាយ និងចែករំលែកគ្នាពន្លឿនការបង្កើតស្ថានការណ៍ទូទៅរចនាសម្ព័ន្ធឧស្សាហកម្មរបៀបផលិតកម្ម និងរបៀបរស់នៅសម្រាប់ការសំចៃធនធាន និង ការពារបរិស្ថាន ដើម្បីទុកពេលនិងចន្លោះឱ្យអេកូ-ធម្មជាតិមានភាពល្អ ប្រសើរឡើងវិញ ៕

ស្វែងយល់អំពីប្រទេសចិនថ្មី៖ នាំយករូបមន្តបណ្តាញអ៊ីនធើណេតចិនទៅប្រទេសកម្ពុជា

ប៉ុន្មានឆ្នាំនេះ វិស័យបណ្តាញអ៊ីនធឺណិត នៃប្រទេសចិនបានទទួលការរីកចម្រើនយ៉ាងឆាប់រហ័សៗការអភិវឌ្ឍនៃបច្ចេកទេសបណ្តាញអ៊ីនធឺណិតបានទាក់ទាញក្រសែភ្នែករបស់ឃុនជនខ្មែរឈ្មោះ ប៊ុន ផាក ។

នៅឆ្នាំ ២០១២ លោក ប៊ុន-ផាក បានមកបន្តការសិក្សានៅសាកល-វិទ្យាល័យធុងជីក្នុងក្រុងស្បៀងហៃនៃប្រទេសចិន ។ លោកបានបញ្ជាក់ថា ក្រោយពីមកដល់ប្រទេសចិនគេបានប្រាប់ខ្ញុំថា អ្នកមិនបាច់ទៅទិញទំនិញនៅផ្សារទេ គ្រាន់តែទិញតាមបណ្តាញអ៊ីនធឺណិតក៏បានហើយពិតជាងាយស្រួលណាស់ ។ កាលនោះ លោកមិនសូវជឿទុកចិត្តលើការទិញទំនិញតាមបណ្តាញអ៊ីនធឺណេតទេ ។ លោកបានសាកល្បងទិញទំនិញម្តងតាមបណ្តាញអ៊ីនធឺណិត ហើយបានទទួលទំនិញ៣ ថ្ងៃក្រោយពីបានបង់ថ្លៃលើវេបសាយ TAOBAO ។

ក្រោយពេលបានទិញទំនិញតាមបណ្តាញអ៊ីនធឺណិតជាលើកទី ១ លោកមានចិត្តរំភើបខ្លាំងណាស់ ហើយសង្ឃឹមថា នឹងអាចមានវេបសាយដូច "TAOBAO" នៅប្រទេសកម្ពុជា ។ នៅឆ្នាំ ២០១៧ លោក ប៊ុន ផាក បានបញ្ចប់ការសិក្សានៅប្រទេសចិន ហើយត្រឡប់ទៅស្រុកខ្មែរវិញ និងចាប់ផ្តើមសិក្សាពីទីផ្សារកម្ពុជា ។ នៅឆ្នាំ២០១៧កិច្ចសហ-ប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និង ពាណិជ្ជកម្មរវាងប្រទេសចិន និងកម្ពុជា បានទទួលការរីកចម្រើនច្រើនគួរឱ្យកត់សម្គាល់ចំណែកគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" បានចាក់បញ្ចូលនូវកម្លាំងចលករថ្មីសម្រាប់ការអភិវឌ្ឍទំនាក់ទំនងចិន-កម្ពុជា ។

ក្រោយពីសិក្សាពីទីផ្សារកម្ពុជា លោកសម្រេចចិត្តថានឹងនាំយករូបមន្តអំពីការទិញទំនិញតាមបណ្តាញអ៊ីនធឺណិតរបស់ចិនមកប្រទេសកម្ពុជា ។ នៅខែមិថុនា ឆ្នាំ ២០១៩ វេបសាយទិញទំនិញPHZAR ដែលបង្កើតដោយលោក ប៊ុន ផាក ចាប់ដំណើរការធ្វើអាជីវកម្មជាផ្លូវការដែលបានសម្រេចនូវរូបមន្តពាណិជ្ជកម្មអន្តរជាតិ "B2B" និង"B2B" រវាងប្រទេសកម្ពុជា និងចិន ។ លោកបានសម្តែងនូវជំនឿចិត្តយ៉ាងរឹងមាំថា សព្វថ្ងៃ"PHZAR" កំពុងស្ថិតនៅក្នុងដំណាក់កាលដំបូង ។ យើងខ្ញុំកំពុងរៀនសូត្រពីរូបមន្តអាជីវកម្មរបស់ក្រុមហ៊ុន ALIBABA និង JD ដើម្បីសម្រេចនូវអាជីវកម្មពហុវិស័យ និងជំរុញឱ្យ PHZAR ក្លាយទៅជាវេបសាយពាណិជ្ជ-កម្មអេឡិចត្រូនិកធំជាងគេនៅប្រទេសកម្ពុជា ។ ក្រៅពីនេះ យើងខ្ញុំសង្ឃឹមថានឹងអាចជំរុញឱ្យជនជាតិខ្មែរកាន់តែច្រើនរៀនចេះការទូទាត់បង់ថ្លៃតាមបណ្តាញអ៊ីនធឺណិត និងទូរស័ព្ទ ។

លោកជឿជាក់ថា ប៉ុន្មានឆ្នាំនេះប្រទេសចិនបាន និងកំពុងកែលម្អគោលនយោបាយពាណិជ្ជកម្មអន្តរជាតិជាបន្តបន្ទាប់ ជាពិសេស កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងចិន បានត្រូវពង្រឹង និងពង្រីកឱ្យកាន់តែស្និតល្មួត ។ កម្ពុជាត្រូវរៀនសូត្រពីរូបមន្តអាជីវកម្មនៃប្រព័ន្ធហៅម្ហូប និងតាក់ស៊ីរបស់ចិន ។ រូបមន្តបណ្តាញអ៊ីនធឺណិតរបស់ចិនគួរឱ្យកោតសរសើរណាស់ ! ទន្ទឹមនឹងការរីកចម្រើននៃកិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងកម្ពុជា ខ្ញុំមុខជានឹងអាចទទួលបាននូវផលប្រយោជន៍ និងការជោគជ័យកាន់តែច្រើនក្នុងការបង្កើតមុខជំនួញរបស់ខ្លួន ៕ **ដោយ លីវ ឃុង**

ខេត្តយូនណានជំរុញការអភិវឌ្ឍវប្បធម៌ថ្មៃប្រឌិតថ្មីតាមរយៈការបើកទូលាយ

ពិព័រណ៍វប្បធម៌ បង្ហាញពីកម្លាំងទាក់ទាញគួរជាទីកត់ សម្គាល់

កាលពីថ្ងៃទី ៨ ដល់ទី ១២ ខែសីហា ឆ្នាំ២០១៩ ពិព័រណ៍ឧស្សាហកម្មវប្បធម៌ថ្មៃប្រឌិតខេត្តយូនណានឆ្នាំ ២០១៩ បានរៀបចំនៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិក្រុងគុនមីងក្រោមប្រធានបទ "ជំរុញការអភិវឌ្ឍតាមរយៈវប្បធម៌លើកកម្ពស់តម្លៃតាមរយៈគំនិតថ្មៃប្រឌិត" ។

ពិព័រណ៍វប្បធម៌លើកនេះបានបង្ហាញឱ្យឃើញពីសមិទ្ធផលនិងនិន្នាការអភិវឌ្ឍន៍ថ្មីនៃឧស្សាហកម្មវប្បធម៌ខេត្តយូនណាន រួមមានពន្លាពិព័រណ៍ចំនួន ៧ គឺពន្លាពិព័រណ៍អភិវឌ្ឍន៍តាមរយៈវប្បធម៌ ពន្លាពិព័រណ៍ថ្មៃប្រឌិតវប្បធម៌ ពន្លាពិព័រណ៍ផ្កានិងពរ្សឹឡែនយូនណាន ពន្លាពិព័រណ៍គំនូរជីវចលនិងការប្រកួតហ្គេមអេឡិចត្រូនិកពន្លាពិព័រណ៍ផលិត-ផលវប្បធម៌ប្រណីតក្រុងផ្សេងៗ ពន្លាពិព័រណ៍ផលិតផលវប្បធម៌ប្រណីតក្រុងគុនមីងនិងសមិទ្ធផលឧស្សាហកម្មវប្បធម៌ ។ ក្រៅពីនេះ នៅមានសាខាពិព័រណ៍ចំនួន៧ ទៀត ដែលរៀបចំនៅក្នុងក្រុងបុវាណាលីជាំង សួនគំនិតថ្មៃប្រឌិតវប្បធម៌យូនហ្វាង សួនសិល្បការ និងតំបន់ទូរណានជាដើមរួមមានរៀបចំសកម្មភាពវប្បធម៌ពិសេសគ្រប់ប្រភេទ ។ សកម្មភាពចំនួន២០ បានត្រូវរៀបចំក្នុងឱកាសនេះ ដែលបានបង្ហាញយ៉ាងពេញលេញអំពីការអភិវឌ្ឍន៍នៃឧស្សាហកម្មវប្បធម៌ខេត្តយូនណាន ។

ការច្របាច់បញ្ចូលគ្នានូវធាតុផ្សំទាន់សម័យ និងបេតិកភណ្ឌវប្បធម៌អរូបីបានធ្វើឱ្យអ្នកទស្សនាមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំង ។ ល្ខោនស្បែក នៃស្រុកយ៉ុងចូវក្រុងធឹងឈុង កម្មវិធីបង្ហាញម៉ូតសម្លៀកបំពាក់ផ្កាឆ្នាំ ២០១៩ និងពិព័រណ៍ស្នាដៃក្រណាត់ប៉ាក់ជាដើម បានទាក់ទាញក្រសែភ្នែករបស់អ្នកទស្សនាដែលមកពីតំបន់ផ្សេងៗ ។ ការច្របាច់បញ្ចូលគ្នានូវវប្បធម៌និងបច្ចេកវិជ្ជាក៏បានធ្វើឱ្យវប្បធម៌ត្រូវបានផ្សព្វផ្សាយឱ្យបានកាន់តែល្អប្រសើរដូចជា "ឃ្លាំងរឿងនិទានមានសំឡេងក្នុងសារមន្ទីរបឹងឈុយហូ" បានបង្ហាញជូនអ្នកទស្សនានូវប្រវត្តិសាស្ត្រនៃបឹងឈុងហូតាមរយៈការប្រើប្រាស់ជារួមនូវអក្សរ រូបភាពសំឡេង និងបរិក្ខារឌីជីថល់ ៕

កូនឃុំវប្បធម៌ និងទេសចរណ៍បង្ហាញក្រមាំងទាក់ទាញចំពោះទេសចរជាតិ និងអន្តរជាតិ

នៅរដូវក្តៅនេះ មណ្ឌល ស្វយ័តជនជាតិយីឈ្ស្បុងបានក្លាយ ទៅជាកន្លែងមួយដែលប្រកបដោយភាពសប្បាយរីករាយ ។ កូនឃុំវប្បធម៌ និងទេសចរណ៍ ពិសេសដែលមានឃុំបុវាណជនជាតិយី តំបន់ដីសើម និងឃុំបុវាណា ជីនសានស្រុកលូហ្វឹងជាដើម ព្រមទាំងវប្បធម៌ទិវាគប់ភ្លើងជនជាតិយីសម្បើកបំពាក់ជនជាតិមាវ និងសិប្បកម្មធ្វើខ្ទុយជនជាតិមាវជាដើមកំពុងទាក់ទាញទេសចរជាតិ និងអន្តរជាតិដ៏ច្រើនមកដើរលេងកម្សាន្ត។ រូបថតនេះបានបង្ហាញពីទេសភាពដ៏ទាក់ទាញនៃឃុំ បុវាណា ជីនសាន ស្រុកលូហ្វឹង ៕

ដោយ យ៉ាវ ឃុង និងលីវ ឃុងណា